ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ......................

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា
## អំពីវិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗ
## នៃសេដ្ឋកិច្ច នៅក្នុងបរិការណ៍នៃវិបត្តិ, ការស្តារ និងជំរុញកំណើន
## សេដ្ឋកិច្ចកម្ពុជា ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩
(ជុំទី៧ , ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០២០)

ការអភិវឌ្ឍវ៉ាក់សាំងមានវឌ្ឍនភាពជាវិជ្ជមាន ហើយប្រទេសមួយចំនួនបាននិងកំពុងចរចា និងសម្រេចធ្វើការបញ្ជាទិញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់ប្រជាជនរបស់ខ្លួន ខណៈដែលប្រទេសមួយចំនួនទៀត រួមទាំងកម្ពុជាផងនោះ បាននិងកំពុងគិតគូរពិចារណា, ពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍នានា និងកំណត់ប្រភពនៃការផ្គត់ផ្គង់វ៉ាក់សាំងពីសំណាក់ក្រុមហ៊ុនផលិតវ៉ាក់សាំងទាំងឡាយណា ដែលមានការទទួលស្គាល់ពីអង្គការសុខភាពពិភពលោក (WHO) អំពីសុវត្ថិភាព, គុណភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់វ៉ាក់សាំងទាំងនោះ ។ ជាមួយនឹងភាពមិនទាន់ច្បាស់លាស់ ១០០% នៃសុវត្ថិភាព, គុណភាព និងប្រសិទ្ធភាពនៃវ៉ាក់សាំងដែលផលិតដោយក្រុមហ៊ុនផ្សេងៗពីគ្នា, លទ្ធភាពនៃការផលិតវ៉ាក់សាំង, ការដឹកជញ្ជូន និងទុកដាក់វ៉ាក់សាំងនៅមានកម្រិត, ពិភពលោកទាំងមូលនៅតែប្រឈមនឹងហានិភ័យខ្ពស់នៅឡើយ ។ម្យ៉ាងវិញទៀត ទោះបីជាមានវ៉ាក់សាំងបង្ការក៏ដោយ ក៏មិនមែនមានន័យថា យើងទាំងអស់គ្នាអាចវិលត្រលប់ទៅប្រក្រតីភាពវិញក្នុងរយៈពេលដ៏ខ្លីបានឡើយ ។ ជាក់ស្តែង, ចាប់តាំងពីមានការរីករាលដាលនៃជំងឺកូវីដ-១៩ មកដល់ពេលនេះ កម្ពុជាបានគ្រប់គ្រងសភាពការណ៍ជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព ទោះបីជាមានព្រឹត្តិការណ៍ថ្ងៃទី ៣ ខែ វិច្ឆិកា និងព្រឹត្តិការណ៍ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលជាការឆ្លងចូលដល់កម្រិតសហគមន៍ជាលើកទី ១ នាពេលថ្មីៗនេះក៏ដោយ ។ ករណីឆ្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ជាលើកដំបូងនេះ បានបណ្តាលឱ្យប្រជាជនមានក្តីព្រួយបារម្ភ ក៏ដូចជាភាពភ័យខ្លាចចំពោះមេរោគដ៏កាចសាហាវនេះយ៉ាងខ្លាំង ប៉ុន្តែរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការមុតស្រួចជាបន្តបន្ទាប់ ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលានៃការរីករាលដាលនៃជំងឺនេះ និងព្យាយាមកុំឱ្យជំងឺនេះរាតត្បាតចូលក្នុងសហគមន៍ដល់កម្រិតមួយដែលមិនអាចគ្រប់គ្រងបាន ។ ជាលទ្ធផល, គិតមកដល់ពេលនេះ កម្ពុជាគ្មានករណីស្លាប់ ឬ ឈានដល់ការដាក់ប្រទេសក្នុងគ្រាមានអាសន្ន ព្រមទាំងមិនមានការបិទជាតំបន់ ឬប្រទេសទាំងមូល នោះឡើយ ។

បន្ទាប់ពីបានពិនិត្យ, ថ្លឹងថ្លែង និងផ្លាស់ប្តូរយោបល់លើស្ថានភាពសង្គម-សេដ្ឋកិច្ច, ពាណិជ្ជកម្ម និងវិនិយោគទាំងក្នុងក្របខណ្ឌសកលលោក, តំបន់ និងក្នុងស្រុក រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការបន្ថែម ជុំទី ៧ ក្នុងគោលបំណង (១). បន្តដាក់ចេញ និងអនុវត្តវិធានការរក្សាលំនឹងអាជីវកម្មខណៈដែលកម្ពុជាកំពុងបន្តប្រឈមនឹងវិបត្តិនៃជំងឺកូវីដ១៩ ក៏ដូចជាទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ច ឱ្យងើបឡើងវិញ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ និង (២). បន្តជួយទំនុកបម្រុងដល់ជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះតាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដើម្បីឆ្លងកាត់ដំណាក់កាលដ៏លំបាកបំផុតនៃវិបត្តិជំងឺកូវីដ១៩ ។ ក្រោយពីបានពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់តួអង្គពាក់ព័ន្ធ និងដោយប្រកាន់ខ្ជាប់នូវស្មារតីបុរេសកម្ម វិធានការជុំទី ៧ ត្រូវបានរៀបចំឡើង និងរួមមានដូចខាងក្រោម ៖

### ១. *វិធានការបន្តជួយវិស័យកាត់ដេរ-វាយនភណ្ឌ, ស្បែកជើង, ផលិតផលធ្វើដំណើរ, កាបូប និងវិស័យទេសចរណ៍*

បន្ទាប់ពីរោងចក្រ-សហគ្រាស និងអាជីវកម្ម ក្នុងវិស័យកាត់ដេរ-វាយនភណ្ឌ, ស្បែកជើង, ផលិតផលធ្វើដំណើរ, កាបូប និងវិស័យទេសចរណ៍ ទទួលបានលិខិតអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ និង/ឬលិខិតអនុញ្ញាតឱ្យពន្យារការព្យួរកិច្ចសន្យាការងារ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោយពីបានបំពេញតាមលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌនៃការព្យួរកិច្ចសន្យាការងារ រាជរដ្ឋាភិបាលកម្ពុជានឹង៖

- បន្តផ្តល់ប្រាក់ឧបត្ថម្ភ ៤០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កម្មករ-និយោជិត ០១ នាក់ ដែលបំពេញការងារក្នុងវិស័យកាត់ដេរ-វាយនភណ្ឌ, ស្បែកជើង, ផលិតផលធ្វើដំណើរ និងកាបូប សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ មករា ដល់ខែ មីនា ឆ្នាំ ២០២១ ។ ម្ចាស់រោងចក្រ-សហគ្រាសក្នុងវិស័យនេះត្រូវបន្ថែមចំនួន ៣០ ដុល្លារអាមេរិក សម្រាប់កម្មករ-និយោជិត ០១ នាក់ (ជាសរុប កម្មករ-និយោជិត ០១ នាក់ ទទួលបាន ៧០ ដុល្លារអាមេរិក ក្នុងមួយខែ) ។
- បន្តផ្តល់ប្រាក់ឧបត្ថម្ភ ៤០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករ-និយោជិត ០១ នាក់ ដែលបំពេញការងារក្នុងវិស័យទេសចរណ៍ ដូចជា៖ សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍ សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ មករា ដល់ខែ មីនា ឆ្នាំ ២០២១ ។ សហគ្រាស និងអាជីវកម្មក្នុងវិស័យទេសចរណ៍ ត្រូវរួមចំណែកតាមគោលការណ៍ស្ម័គ្រចិត្ត និងតាមលទ្ធភាពជាក់ស្តែង បន្ថែមលើអ្វីដែលរាជរដ្ឋាភិបាលបានផ្តល់ជូន ។
- បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ ចំពោះសណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានីភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្តកែប, ខេត្តកំពត, ក្រុងបាវិត និងក្រុងប៉ោយប៉ែត សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ មករា ដល់ខែ មីនា ឆ្នាំ ២០២១ ។ អាជីវកម្មទាំងនេះ នៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និងប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម (E-VAT) ជារៀងរាល់ខែ ក្នុងអំឡុងពេលនៃការលើកលែងនេះ ។

- បន្តពន្យារការចាប់ផ្តើមអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធន រយៈពេល ០៦ ខែ បន្តទៀត គឺរហូតដល់ខែ កក្កដា ឆ្នាំ ២០២១ ។ ការពន្យារពេលនេះនឹងត្រូវផ្អែកលើការវាយតម្លៃជាបន្តបន្ទាប់នូវស្ថានភាពសង្គម-សេដ្ឋកិច្ចជាក់ស្តែង ។
- បន្តលើកលែងការបង់ភាគទានរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព នៃបេឡាជាតិសន្តិសុខសង្គម ក្នុងអំឡុងពេលព្យួរអាជីវកម្ម ឬផ្អាកដំណើរការអាជីវកម្ម ។
- បន្តលើកលែងការបង់ពន្ធប៉ាតង់ និងពន្ធលើតែមប្រើសារពើពន្ធ (ពន្ធលើស្លាកយីហោ) ចំពោះក្រុម-ហ៊ុនភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ដទៃទៀត ។ អ្នកជាប់ពន្ធទាំងនេះ មានកាតព្វកិច្ចត្រូវធ្វើបច្ចុប្បន្នភាពប៉ាតង់ ។
- កំណត់ឱ្យអ្នកជាប់ពន្ធក្នុងវិស័យទេសចរណ៍ ដូចជា៖ សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានីភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្តកែប, ខេត្តកំពត, ក្រុងបាវិត និងក្រុងប៉ោយប៉ែត ដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២០ យ៉ាងយឺតបំផុតឱ្យបានមុនដំណាច់ខែ មីនា ឆ្នាំ ២០២១ ប៉ុន្តែមិនតម្រូវឱ្យបង់ពន្ធគ្រប់ប្រភេទ ។

## ២. វិធានការបន្តជួយវិស័យអាកាសចរណ៍

- បន្តលើកលែងការបង់ពន្ធអប្បបរមា (Minimum Tax) សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ មករា ដល់ខែ មីនា ឆ្នាំ ២០២១ ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ ដែលបានចុះបញ្ជីនៅកម្ពុជា ។
- បន្តពន្យារការបង់ប្រាក់ជំពាក់កម្រៃអាកាសចរស៊ីវិល សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ មករា ដល់ខែ មីនា ឆ្នាំ ២០២១ ជាមួយនឹងការអនុញ្ញាតឱ្យក្រុមហ៊ុនអាកាសចរណ៍ទាំងនោះរៀបចំបង់ប្រាក់ជំពាក់នោះ ជាដំណាក់កាល ក្រោយពីរយៈពេលពន្យារនេះ ។

## ៣. វិធានការជួយរោងចក្រ, សហគ្រាស និងអាជីវកម្ម ក៏ដូចជាជួយសម្រួលដល់ជីវភាពរស់នៅរបស់កម្មករ-និយោជិត

- បន្តអនុញ្ញាតឱ្យរោងចក្រ, សហគ្រាស និងអាជីវកម្មក្នុងគ្រប់វិស័យ ពន្យារពេលទូទាត់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ ២០១៩ និងការទូទាត់ប្រាក់បំណាច់អតីតភាពការងារសម្រាប់ឆ្នាំ ២០២០ និង ២០២១ ទៅឆ្នាំ ២០២២ ។ ប្រសិនបើស្ថានភាពសង្គម-សេដ្ឋកិច្ចត្រឡប់មកប្រក្រតីវិញ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវបើកកិច្ចពិភាក្សាជាមួយនឹងរោងចក្រ, សហគ្រាស និងអាជីវកម្ម ដើម្បីកំណត់នីតិវិធី និងធ្វើការទូទាត់ជាដំណាក់កាលៗ ។ ក្នុងករណីដែលផលប៉ះពាល់មិនមានការថមថយ, រាជរដ្ឋាភិបាលនឹងគិតគូរជាជម្រើសជួយដល់រោងចក្រ-សហគ្រាស, អាជីវកម្ម និងនិយោជិត ។

## ៤. វិធានការទ្រទ្រង់កំណើន

- បន្តលើកលែងពន្ធប្រថាប់ត្រាសម្រាប់អ្នកទិញផ្ទះដែលមានថ្លៃទាបជាង ឬស្មើប្រាំពីរម៉ឺនដុល្លារអាមេរិក ដោយគិតពីខែ មករា ឆ្នាំ ២០២១ ដល់ដំណាច់ខែ ធ្នូ ឆ្នាំ ២០២១ ពីក្រុមហ៊ុនអភិវឌ្ឍន៍លំនៅដ្ឋាន ដែលចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង/ឬ នៅតាមមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទន្ទឹមនេះ,

រាជរដ្ឋាភិបាលក៏សូមអំពាវនាវដល់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅដ្ឋានទាំងអស់ ឱ្យចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការបញ្ចុះថ្លៃផ្ទះ ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

### *៥. ការបន្ធូរបន្ថយការអនុវត្តពន្ធកាត់ទុកលើការប្រាក់សម្រាប់អ្នកផ្តល់កម្ចីក្នុងស្រុក និងក្រៅស្រុក (Withholding Tax)*

- សម្រាប់កម្ចីថ្មី៖
  - ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និងខាងក្នុងស្រុក, មកនៅត្រឹម ៥% ( ទាំងការខ្ចីពីប្រទេសដែលមាន DTA និង ការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២១ ។
  - ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និងខាងក្នុងស្រុក, មកនៅត្រឹម ១០% (ទាំងការខ្ចីពីប្រទេសដែលមាន DTA និងការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២២ ។
  - ពិនិត្យ និងកែតម្រូវអត្រាពន្ធកាត់ទុក លើកម្ចីធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និងខាងក្នុងស្រុក, ឱ្យឡើងដល់កម្រិតធម្មតា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានវិញ នៅឆ្នាំ ២០២៣ ។
- សម្រាប់កម្ចីចាស់៖
  - ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និងខាងក្នុងស្រុក, មកនៅត្រឹម ១០% ( ទាំងការខ្ចីពីប្រទេសដែលមាន DTA និងការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២១ ។
  - ពិនិត្យ និងកែតម្រូវអត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភេទខាងក្រៅ និងខាងក្នុងស្រុក, ឱ្យឡើងដល់កម្រិតធម្មតាស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានវិញ នៅឆ្នាំ ២០២២ ។

### *៦. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ*

- បន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត គឺពីខែ មករា ដល់ខែ មីនា ឆ្នាំ ២០២១ ។

ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តនូវសេចក្តីណែនាំនេះ ទៅតាមសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

រាជរដ្ឋាភិបាលនឹងបន្តតាមដានជាប់ជាប្រចាំនូវស្ថានភាពនៃជំងឺកូវីដ-១៩, លើស្ថានភាពសង្គម-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងក្របខណ្ឌសកលលោក, តំបន់ និងក្នុងប្រទេស ដើម្បីពិនិត្យ និងវាយតម្លៃពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា ក្នុងទិសដៅធ្វើបច្ចុប្បន្នភាព និងត្រៀមដាក់ចេញនូវវិធានការថ្មីៗបន្ថែមចាំបាច់នានា ក្រោមក្របខណ្ឌផែនការយុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឡើងវិញក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ។

ឈឈឈ៚៙៙៙